ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ៨៦
ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ ២០២៣
សញ្ញាណនៃរឿងក្តី៖ ទាមទារប្រាក់
សាលក្រមរដ្ឋប្បវេណីលេខ ១៧ "ជ"
ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣

# សាលក្រម

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ធំ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តកំពង់ធំ

**ដើមចោទ**

ឈ្មោះ [redacted] **ផេង** ភេទប្រុស កើតថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៨៩ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]។

**សហចុងចម្លើយ**

ឈ្មោះ [redacted] **ប៉ាក់** ភេទប្រុស ជាតិខ្មែរ កើតថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៨០ ទីលំនៅបច្ចុប្បន្ន [redacted]។

ឈ្មោះ [redacted] **ណេង** ជាតិខ្មែរ កើតថ្ងៃទី០៦ ខែកក្កដា ឆ្នាំ១៩៨៣ ទីលំនៅបច្ចុប្បន្ន [redacted]។

**អ្នកតំណាងដោយអាណត្តិរបស់សហចុងចម្លើយ**

លោកមេធាវី [redacted] អត្តលេខ ២៦៣៦T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការការិយាល័យមេធាវី [redacted] ដែលមានអាសយដ្ឋានស្ថិតនៅ [redacted]។

## អង្គហេតុ និងការអះអាងរបស់គូភាគី

### ១. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

ក.ទាមទារប្រាក់ថ្លៃឈ្នួលធ្វើផ្ទះ និងថ្លៃសម្ភារៈធ្វើផ្ទះ សរុប ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីររយ) រៀល។



Scanned with CamScanner

ខ.ទាមទារសំណងជម្ងឺចិត្ត និងខាតបង់ពេលវេលា សរុបចំនួន ៥.០០០$ (ប្រាំពាន់) ដុល្លារអាមេរិក ។

គ.សុំប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុចទី១ នៃខ្លឹមសារទាមទារ។

ឃ.ប្រាក់ប្រដាប់ក្តីជាប្រាក់របស់ចុងចម្លើយ។

## ២. អង្គហេតុ និងចំណុចវិវាទ

### ២.១. អង្គហេតុនៃដំណើររឿង

នៅក្នុងរឿងក្តីនេះ ដើមចោទបានអះអាងថាកាលពីខែមិថុនា ឆ្នាំ២០២២ សហចុងចម្លើយឈ្មោះ[redacted] ប៉ាក់ និងឈ្មោះ [redacted]ណោ បានជួលដើមចោទឱ្យសាងសង់ផ្ទះឱ្យ ដែលមានទំហំ ២២ (ម្ភៃពីរ) ម៉ែត្រ គុណនឹង ៧ (ប្រាំពីរ) ម៉ែត្រ ជាផ្ទះទៀម ស្ថិតនៅភូមជន្លុះ ឃុំទួលគ្រើល ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ក្នុងតម្លៃសរុបទាំងសម្ភារៈ និងថ្លៃឈ្នួល ចំនួន ១១.០៥០ (មួយម៉ឺនមួយពាន់ហាសិប) ដុល្លារអាមេរិក ស្មើនឹង ៤៥.៣០៥.០០០ (សែសិបប្រាំលានបីរយសូន្យប្រាំពាន់) រៀល ដោយបានធ្វើកិច្ចព្រមព្រៀងចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ ជាភស្តុតាង។ បន្ទាប់ពីបានព្រមព្រៀងលើតម្លៃហើយ ដើមចោទក៏បានធ្វើការសាងសង់ តែសហចុងចម្លើយឈ្មោះ [redacted] ប៉ាក់ និងសហចុងចម្លើយឈ្មោះ [redacted]ណោ មិនអនុវត្តតាមការព្រមព្រៀងលើការប្រគល់ប្រាក់ឱ្យបានត្រឹមត្រូវនោះទេ គឺបានឱ្យថ្លៃឈ្នួល និងសម្ភារៈ នៃការសាងសងផ្ទះ សរុបតែចំនួន ១៩.៨១២.៣០០ (ដប់ប្រាំបួនលានប្រាំបីរយដប់ពីរពាន់បីរយ) រៀល ប៉ុណ្ណោះ។ សហចុងចម្លើយត្រូវនៅជំពាក់ប្រាក់ដើមចោទចំនួន ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីររយ) រៀល មិនព្រមសងទេ។ រហូតដល់សព្វថ្ងៃនេះ រាល់ដែលពេលដើមចោទទារប្រាក់នេះសហចុងចម្លើយចេះតែដោះសារ ថ្ងៃនេះ ថ្ងៃនោះមិនចេះចប់ ទីបំផុតគឺសហចុងចម្លើយមិនព្រមសងតែម្តង អស់រយៈពេល ០១ (មួយ) ឆ្នាំមកហើយ។ ផ្ទះរបស់សហចុងចម្លើយ ដើមចោទបានចាប់ផ្តើមធ្វើពីខែមិថុនា ឆ្នាំ២០២២ ដល់ខែវិច្ឆិកា ឆ្នាំ២០២២ ត្រូវបានរួចរាល់ជាស្ថាពរ។ នៅពេលដែលសហចុងចម្លើយដែលជាម្ចាស់ផ្ទះមិនព្រមសងប្រាក់មកឱ្យដើមចោទ ធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ដើមចោទយ៉ាងធ្ងន់ធ្ងរ ពីព្រោះសម្ភារៈទាំងអស់ដើមចោទទិញមកជំពាក់គេ គិតថាចាំយកប្រាក់ថ្លៃឈ្នួលផ្ទះនេះមកសងគេ ពេលធ្វើរួច តែបែរឥឡូវត្រូវគេគិតការប្រាក់ពីដើមចោទ ធ្វើឱ្យដើមចោទខាតបង់ប្រាក់ និងពេលវេលា សោហ៊ុយផ្សេងៗដែលត្រូវចំណាយលើការប្តឹងនេះទៀតផង។ ហេតុនេះ ដើមចោទបានដាក់ពាក្យស្នើសុំឱ្យតុលាការចេញសាលក្រមដូចការទាមទារនៅក្នុងពាក្យបណ្តឹងខាងលើ។

សហចុងចម្លើយ បានអះអាងតបថា សហចុងចម្លើយទទួលស្គាល់លុយនៅសល់ជំពាក់ ដើមចោទចំនួន សរុប ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីររយ) រៀល ចំពោះប្រាក់នេះសហចុងចម្លើយមិនព្រមបង់ឱ្យដោយសារតែដើមចោទធ្វើផ្ទះឱ្យសហចុងចម្លើយមិនបានល្អ ដោយមានការប្រេះ ទ្រេត និងស្រុត ដែលសហចុងចម្លើយមិនអាចទទួលយកបានទេ ហើយពេលសហចុងចម្លើយកម្មង់សាងសង់ និងប្រាប់ ដើមចោទ មិនដែលធ្វើតាមសហចុងចម្លើយទេ។ ដើមចោទមិនបានធ្វើផ្ទះសហចុងចម្លើយបានល្អទេ និងមានការប្រេះ ទ្រេត ស្រុតទៀតផង ហើយមិនបានធ្វើតាមការនិយាយគ្នានោះទេ ពេលសហចុងចម្លើយកម្មង់អ្វីមិនដូចចិត្តទេ ហើយផ្ទះដែលធ្វើនោះមិនទាន់រួចជាស្ថាពរទេ តែបែមកទារប្រាក់សហចុងចម្លើយទៅវិញ។



Scanned with CamScanner

### ២.២. អង្គហេតុគ្មានវិវាទ

សហចុងចម្លើយឈ្មោះ [redacted]ប៉ាក់ និងឈ្មោះ [redacted]ណោ សារភាពថាប្រាក់ជំពាក់ថ្លៃជាងនៅសល់ចំនួន ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីររយ) រៀល ដែលមិនទាន់បានបង់ឱ្យទៅដើមចោទឈ្មោះ [redacted]ផេត ។

### ២.៣. ការអះអាងរបស់ភាគីទាក់ទងនឹងចំណុចវិវាទ និងចំណុចវិវាទ

#### ចំណុចវិវាទ ទី០១

##### ក. ការអះអាងរបស់ដើមចោទ

កាលពីថ្ងៃខែមិថុនា ឆ្នាំ២០២២ សហចុងចម្លើយបានជួលដើមចោទឱ្យសាងសង់ផ្ទះឱ្យសហចុងចម្លើយ ដែលមានទំហំ ២២ ម៉ែត្រ គុណនឹង ៧ ម៉ែត្រ ជាផ្ទះទៀម ស្ថិតនៅភូមិជន្លុះ ឃុំទួលក្រើល ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ក្នុងតម្លៃ ៤៥.៣០៥.០០០៛ (សែសិបប្រាំលានបីរយប្រាំពាន់) រៀល ដោយគិតទាំងសម្ភារៈ និងឈ្នួលធ្វើ ហើយសហចុងចម្លើយក៏ព្រមព្រៀងឱ្យដើមចោទធ្វើការសាងសង់។ បន្ទាប់ពីបានសាងសង់រួចបែរជាសហចុងចម្លើយ មិនបានអនុវត្តតាមការព្រមព្រៀងលើការប្រគល់ប្រាក់ឱ្យត្រឹមត្រូវនោះទេ គឺបានឱ្យត្រឹមតែ ១៩.៨១២.៣០០៛ (ដប់ប្រាំបួនលានប្រាំបីរយដប់ពីរពាន់បីរយ) រៀល ប៉ុណ្ណោះ នៅសល់ជំពាក់ប្រាក់ដើមចោទចំនួន ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីររយ) រៀល ដែលមិនទាន់ឱ្យគ្រប់។ ដើមចោទ និងសហចុងចម្លើយ ក៏ធ្លាប់បានទៅដោះស្រាយនៅប៉ុស្តិ៍ បន្ទាប់មក ដើមចោទ និងសហចុងចម្លើយក៏កិច្ចព្រមព្រៀង ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ ហើយសហចុងចម្លើយបានអនុវត្តតាមការសន្យានោះទេ។

##### ខ. ការអះអាងរបស់សហចុងចម្លើយ

សហចុងចម្លើយ អះអាងថា បដិសេធ ការទាមទាររបស់ដើមចោទ។

##### គ. អង្គហេតុវិវាទ

ការអនុវត្តកាតព្វបានពេញលេញតាមការព្រមព្រៀងសាងសង់។

#### ចំណុចវិវាទ ទី០២

##### ក. ការអះអាងរបស់ដើមចោទ

ដើមចោទសុំទាមទារសំណងខូចខាតជំងឺចិត្តចំនួន ៥.០០០ $ (ប្រាំពាន់) ដុល្លារអាមេរិក ព្រោះការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយធ្វើឱ្យដើមចោទ ខាតបង់ពេលវេលា និងខកខានការទូរទាត់ឱ្យខាងដេកប៉ូសំណង់ និងថ្លៃកម្មករ ដែលដើមចោទត្រូវរ៉ាប់រង ជាពិសេសត្រូវសងការប្រាក់ទៅឱ្យខាងដេប៉ូទៀតផង ក្នុងការ ០.៥% ក្នុងមួយខែ។

##### ខ. ការអះអាងរបស់សហចុងចម្លើយ

សហចុងចម្លើយ អះអាងថា បដិសេធ ការទាមទាររបស់ដើមចោទ។

##### គ. អង្គហេតុវិវាទ

សំណងជំងឺការខូចខាតចំនួន ៥.០០០$ (ប្រាំពាន់) ដុល្លារអាមេរិក។



Scanned with CamScanner

## <u>សំអាងហេតុ</u>

### ១. ការវិនិច្ឆ័យអំពីចំណុចវិវាទ

**ក.ចំណុចវិវាទទី១**

ដើមចោទបានបង្ហាញថា កាលពីថ្ងៃខែមិថុនា ឆ្នាំ២០២២ សហចុងចម្លើយបានជួលដើមចោទឱ្យសាងសង់ផ្ទះឱ្យសហចុងចម្លើយ ដែលមានទំហំ ២២ ម៉ែត្រ គុណនឹង ៧ ម៉ែត្រ ជាផ្ទះទៀម ស្ថិតនៅភូមិជន្លុះ ឃុំទួលគ្រើល ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ក្នុងតម្លៃ ៤៥.៣០៥.០០០៛ (សែសិបប្រាំលានបីរយប្រាំពាន់) រៀល ដោយគិតទាំងសម្ភារៈ និងឈ្នួលធ្វើ ហើយសហចុងចម្លើយក៏ព្រមព្រៀងឱ្យដើមចោទធ្វើការសាងសង់។ បន្ទាប់ពីបានសាងសង់រួចបែរជាសហចុងចម្លើយ មិនបានអនុវត្តតាមការព្រមព្រៀងលើការប្រគល់ប្រាក់ឱ្យត្រឹមត្រូវនោះទេ គឺសហចុងចម្លើយបានឱ្យត្រឹមតែ ១៩.៨១២.៣០០៛ (ដប់ប្រាំបួនលានប្រាំបីរយដប់ពីរពាន់បីរយ) រៀល ប៉ុណ្ណោះ នៅសល់ជំពាក់ប្រាក់ដើមចោទចំនួន ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីររយ) រៀល ដែលមិនទាន់ឱ្យគ្រប់។ ដើមចោទ និងសហចុងចម្លើយ ក៏ធ្លាប់បានទៅដោះស្រាយនៅប៉ុស្តិ៍ បន្ទាប់មក ដើមចោទ និងសហចុងចម្លើយក៏កិច្ចព្រមព្រៀង ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២២ ហើយសហចុងចម្លើយបានអនុវត្តតាមការសន្យានោះទេ។

សាក្សីឈ្មោះ [redacted]ភាព និងឈ្មោះ [redacted]អុល បានបង្ហាញថា ខ្លួនពិតជាកម្មធ្វើផ្ទះឱ្យសហចុងចម្លើយ ដោយខ្លួនមិនបានទទួលប្រាក់ថ្លៃពលកម្មពីដើមចោទនោះទ ហើយចំពោះរឿងលុយដែលសហចុងចម្លើយត្រូវទូទាត់ឱ្យដើមចោទថ្លៃសាងសង់ផ្ទះឱ្យខ្លួនមិនបានដឹងទេ។

អ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ អះអាងថា បដិសេធ ការទាមទាររបស់ដើមចោទ។

ផ្អែកតាមភស្តុតាង និងការសាកសួរសាមីភាគី យល់ឃើញថា ដើមចោទបានអនុវត្តកាតព្វកិច្ចសាងសង់ផ្ទះជូនសហចុងចម្លើយរួចហើយ។

**ខ.ចំណុចវិវាទទី២**

ដើមចោទ បានបង្ហាញថា ដើមចោទទាមទារសំណងខូចខាតជំងឺចិត្តចំនួន ៥.០០០ $ (ប្រាំពាន់) ដុល្លារអាមេរិក ព្រោះការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយធ្វើឱ្យដើមចោទ ខាតបង់ពេលវេលា និងខកខានការទូរទាត់ឱ្យខាងដេប៉ូសំណង់ និងថ្លៃកម្មករ ដែលដើមចោទត្រូវរ៉ាប់រង ជាពិសេសត្រូវសងការប្រាក់ទៅឱ្យខាងដេប៉ូទៀតផងក្នុងការ ០.៥% ក្នុងមួយខែ។

អ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ អះអាងថា បដិសេធ ការទាមទាររបស់ដើមចោទ។

យល់ឃើញថា ការមិនបង់ប្រាក់របស់សហចុងចម្លើយធ្វើឱ្យមានការខូចខាតដល់ដើមចោទ។

### ២. ការវិនិច្ឆ័យអំពីការទាមទារ

២.១. យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ ដើម្បីទទួលស្គាល់ថាសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទចំនួន ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីរពាន់ប្រាំពីររយ) រៀល ដុល្លារអាមេរិក។

២.២. យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ ដើម្បីទទួលស្គាល់ថា ដើមចោទទទួលរងការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយ។

២.៣. យល់ឃើញថា ការទាមទារទី១ និងទី ២ របស់ដើមចោទ មានមូលហេតុត្រឹមត្រូវ។



Scanned with CamScanner

២.៤. យល់ឃើញថា ការទាមទារទី១ របស់ដើមចោទ គឺជាការទាមទារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ហើយសហចុងចម្លើយបានសារភាពនូវចំនួនទឹកប្រាក់ដែលបានជំពាក់នេះ គប្បីតុលាការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន តាមបញ្ញត្តិមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

២.៥. យល់ឃើញថា ប្រាក់ប្រដាប់ក្ដីដែលដើមចោទ និងសហចុងចម្លើយបានបង់គឺជាបន្ទុករបស់សហចុងចម្លើយតាមបញ្ញត្តិមាត្រា ៦៤ និងមាត្រា ៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ហេតុដូច្នេះ តុលាការ ធ្វើការវិនិច្ឆ័យ និងសម្រេចដូចខាងក្រោម៖

<u>**សេចក្ដីសម្រេចបញ្ចប់**</u>

១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ គួន ប៉ាក់ និងឈ្មោះ [redacted] ណេ សងប្រាក់ចំនួន ២៥.៤៩២.៧០០ (ម្ភៃប្រាំលានបួនរយកៅសិបពីរពាន់ប្រាំពីររយ) រៀល ទៅឱ្យដើមចោទឈ្មោះ [redacted] ផេត។

២.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ប៉ាក់ និងឈ្មោះ [redacted] ណេ សងប្រាក់ចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល (ដែលជាសំណងជម្ងឺចិត្ត) ទៅឱ្យដើមចោទឈ្មោះ [redacted] ផេត។

៣.ប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្នត្រង់សេចក្ដីសម្រេចទី១ នៃសាលាក្រមនេះ។

៤. ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់សហចុងចម្លើយឈ្មោះ [redacted] ប៉ាក់ និងឈ្មោះ [redacted] ណេ។

គូភាគីអាចប្ដឹងឧទ្ធរណ៍ ចំពោះសាលក្រមនេះ តាមបញ្ញត្តិច្បាប់។

សាលក្រមនេះ បានប្រកាសនៅក្នុងសវនាកាជាសាធារណៈ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។

ថ្ងៃពុធ ១១កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ខេត្តកំពង់ធំ, ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

“បានចម្លងត្រឹមត្រូវតាមច្បាប់ដើម”

ថ្ងៃពុធ ១១កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ពស. ២៥៦៧

ខេត្តកំពង់ធំ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner